# វគ្គទី៤

លោកពន្លឺ លោកគ្រូសុភា វិចិត្រ មរកតឈរនៅចំណតអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្នុងអាការៈរង់ចាំទទួលនរណាម្នាក់ ។ លោកពន្លឺមានរស្មីភក្ត្រស្រស់ថ្លា លោកនិយាយតិចៗទៅកាន់លោកគ្រូសុភា :

-សុភា ! ខ្ញុំឃើញក្មួយស្រីមរកតសុភាពរាបសារអ៊ីចឹង ខ្ញុំច្រណែនឯងណាស់ណាំដឹងទេ ។

-ច្រណែនរឿងអីហ្នាពន្លឺ ខ្ញុំដូចជាវង្វេងស្មាប់ស្មាប់សំដីឯងមិនយល់មែនណាំ ?

-គឺវាអ៊ីចេះ ខ្ញុំមានកូនស្រីតែម្នាក់ដែលកំព្រាម្តាយដូចកូនស្រីឯងដែរ តែខ្ញុំគ្មានកូនស្រី ដែលមានលក្ខណៈជានារីខ្មែរស្រគត់ស្រគំដូចក្មួយស្រីមរកតនោះសោះ ។

-តែយ៉ាងណាក្មួយស្រីកេសរីបានរស់នៅបរទេស តាំងពីតូចក្រូចឆ្មាមកហើយ នាងត្រូវតែជុះទំលាប់បែបបរទេសនិយម ម្យ៉ាងនាងជាតារាភាពយន្តល្បីដែលត្រូវមានបែបផែននៃការរស់នៅតាមលក្ខណៈខ្លះជាសិល្បករអ៊ីចឹងហើយ ។ ទោះម្តេចម្តាកូនស្រីរបស់ឯងជាចំណែកនៃជំនួយដ៏ធំមួយ ក្នុងរបរផលិតភាពយន្តនិងខារ៉ាអូខេរបស់ឯងណាំ។ ឯងនៅមានអ្វីមិនពេញចិត្តចំពោះទង្វើរបស់កូនឯងទៀតនោះ ពន្លឺ ?

-ពិតណាស់កេសរីជាតារាភាពយន្តឯកប្រចាំផលិតកម្មរបស់ខ្ញុំ និងជាតារាឯកសំរាប់ការថតរឿង ដែលនិពន្ធឡើងដោយក្មួយវិចិត្រលើកនេះផង ។ ខ្ញុំពេញចិត្តនូវចំណុចនេះដែលកេសរីបានជួយខ្ញុំ តែភាពនិយមរបស់គេម្តងម្កាលខ្ញុំដូចជាទើសទាល់ ... តែ... ហ៊ឺ!....គេមិនតាមខ្ញុំសោះ លើចំណុចជំទាស់ចិត្តខ្ញុំនេះណាំសុភា ។ ខ្ញុំគិតថា កូនស្រីខ្ញុំមានការខុសឆ្គងក្នុងនាមគេជាស្រីខ្មែរមួយរូប ... ហេតុអីគេមិនគិតថាជីវិតជាតារាវាស្ថិតតែលើការសំដែង តែនេះនាងប្រើជាជីវិតមែនទែន ឱ្យឡូកឡំទៅនឹងជីវិតសំដែងតែម្តង ។

-ឈប់ត្រឹមនេះចុះពន្លឺ ក្តាយល់ពីបំណងឯង តែថាកេសរីនៅក្មេងណាស់ ឯងត្រូវទុកពេលសំរាប់នាងផង ព្រោះក្តាយល់ថាស្លឹកឈើជ្រុះមិនឆ្ងាយពីគល់ទេ ។

-តែខ្យល់កំពុងបក់ផាត់ស្លឹកឈើឱ្យឃ្លាតឆ្ងាយពីគល់ហើយសុភាអើយ ។

-ផ្លែស្វាយគឺជាស្វាយ មិនអាចក្លាយជាក្រូចឡើយពន្លឺ ។

-ក្តាសុំឱ្យដូចសំដីឯងចុះ ។

ភ្លាមនោះស្ទើរមិនទាន់ចប់ប្រយោគលោកពន្លឺស្រូលបួលផង សំលេងស្រួយស្រេះរបស់កញ្ញាម្នាក់ លាន់កាត់ហ្វូងទេសចរណ៍នានា ដែលកំពុងដើរចេញពីក្នុងអាគារនៃអាកាសយានដ្ឋាន បានហើរមកប៉ះត្រចៀកលោកពន្លឺ :

-ប៉ាប៉ា ! កេសរីមកហើយ ។

ទាំងលោកពន្លឺ ទាំងលោកសុភា មរកត និងវិចិត្រងាកតម្រង់ប្រភពសួរ នៃគ្រាមនុស្សទាំងបួននាក់យល់ជាក់កញ្ញារូបសោភាក្នុងវ័យ១៩ឆ្នាំ ប្រកប ដោយសំពត់រូបមីនីពណ៌ក្រហមឆេះ ខើចពាក់កណ្តាលភ្លៅ មុខធីតាផាត់ម្សៅ គួសចិញ្ចើម លាបត្របកភ្នែកខៀវជាំ ។ ការតុបតែងកាយនេះ បង្ហាញពីភាព ជាក្រមុំទំនើបនៃការរស់នៅបែបនារីបរទេស ។ទោះជាការរៀបចំខ្លួនរបស់កញ្ញា មានភាពឆើតឆាយក៏ពិតមែន តែយើងមិនអាចបដិសេធពីសម្រស់ផូរផង់របស់ នាងឡើយ ។ នាងជាកេសរី ...ស្រីរត់កាត់ហ្វូងមនុស្សទាំងលើកហត្ថាត្រវី ជា មួយស្នាមសើចពព្រាយលើបបូរមាត់ក្រហមស្រស់ ដោយការលាបលនក្រេម ។ ស្រីរត់តម្រង់មករកលោកពន្លឺ ។ ម្ចាស់រោងពុម្ព "កេសរី "លើកដៃត្រវីតប ទៅរកបុត្រី ។ កេសរីរត់មកស្រវាអោបបិតា ទាំងនាងថើបថ្ពាល់ទាំងពីរ របស់ ឪពុក ដោយនួននាងវាចា :

-កេសរីនឹកប៉ាប៉ា ! កេសរីចង់ស្គាល់លោកវិចិត្រដែលជាអ្នកនិពន្ធ អស្ចារ្យបំផុតរបស់ប៉ាប៉ាណាស់ ។

នាងឈប់ថើបបិតា សំលឹងមើលមុខលោកពន្លឺ សួរយ៉ាងរន្ធើន :

-លោកវិចិត្រនៅឯណាប៉ាប៉ា ? កូនចង់ឃើញមុខគេ តើស្រស់សង្ហាដូច បងបូរ៉ាតារាឯកប្រុស របស់ផលិតកម្មយើងនៅឯអាមេរិកនោះទេប៉ាប៉ា ?

នៅអាមេរិកផលិតកម្មលោកពន្លឺផលិតជាខារ៉ាអូខេ ដែលមានកេសរី ជាតួឯកស្រី និងកំលោះបូរ៉ា ជាមិត្តរួមមហាវិទ្យាល័យរបស់នាងជាតារាឯក ប្រុស ។ បូរ៉ាមានរូបសង្ហា មានទ្រព្យធនមិនចាញ់កេសរីទេ តែគេមានវ័យលើស

កេសរីចំនួន៧ឆ្នាំ ។ គេទាំងពីរមាននិស្សយ័ស្រលាញ់សិល្បៈដូចគ្នា ។ បូរ៉ាមានគំនិតចាស់ទុំ និងមានទំនោរចំនូលចិត្តស្រលាញ់អ្វី១ជាទំនៀមទំលាប់ខ្មែរជាជាងកេសរី ។ ប៉ុន្តែបូរ៉ាជាមនុស្សមានអធ្យាស្រ័យ តែងអត់ឱនជានិច្ចដល់អ្នកដទៃ ។ គេជាមនុស្សផ្តល់ឱកាសសំរាប់មិត្តភក្តិ គេមិនចូលចិត្តវាយតម្លៃមនុស្សតែសំបកក្រៅឡើយ។ សំរាប់រូបគេ បើនរណាខុសនៅថ្ងៃនេះ គេសុទិដ្ឋិជានិច្ចថា អ្នកនោះអាចនឹងលែងខុសទៀតនៅថ្ងៃស្អែក ។ បូរ៉ាល្អសំរាប់ភ្នែកលោកពន្លឺ លោកទុកចិត្តលើកំលោះនេះ លោកយល់ថា អ្នកប្រុសអាចនឹងកែប្រែកូនស្រីគាត់ឱ្យក្លាយជាមនុស្សស្រីដ៏ប្រពៃម្នាក់សំរាប់លោក សំរាប់ខ្លួននាងជាជាតិខ្មែរ ។ បូរ៉ាបានសន្យានូវខនេះ ជាមួយលោក ត្បិតបូរ៉ាប្រាថ្នាកេសរីជាគូជីវិតសំរាប់ពេលអនាគត ។ ដូចនេះនារីជាគូរួមជីវិតគេ ត្រូវតែមានអ្វី១ដូចគេ ។ តែពីរបីឆ្នាំមកហើយ បូរ៉ាមិនអាចកែប្រែកេសរីរបស់លោកពន្លឺបានសោះ ។ តែទោះជាយ៉ាងនេះក៏ដោយ បូរ៉ាបានរក្សាសន្យា ដោយដក់ជាប់នូវក្តីសង្ឃឹមជានិច្ច ចំពោះលោកពន្លឺនិងចំពោះបេះដូងប្រាថ្នារបស់ខ្លួន ។

កាលបើឮសំនូនបុត្រីសួររកកំលោះអ្នកនិពន្ធ ដោយប្រយោគគួរឱ្យ ស្រគៀត្រចៀក លោកពន្លឺលបចោលភ្នែកទៅរកលោកសុភា ជាក្រសែភ្នែកបង្ហាញនូវការហួសចិត្តចំពោះឫកពាបុត្រី ។ បិតាមរកតធ្វើមុខញញឹម១គ្រវីក្បាលតិច១ ជាសញ្ញាទប់ការទើសចិត្តរបស់ឪពុកកេសរី ។លោកពន្លឺញញឹមស្ងើរ ជាកិច្ច

ទទួលការលើកទឹកចិត្តពីមិត្ត ។ លោកបែរពីមើលលោកសុភា ងាកមុខមករក កូនស្រីវិញ :

- កូនស្រី គេមិនវាស់តម្លៃមនុស្សលើភាពស្រស់សង្ហានោះទេកូន ។

ចប់ឃ្លាខាងលើ និងមិនរង់ចាំការឆ្លើយតបរបស់កេសរី លោកពន្លឺងាក មកវិចិត្រដែលកំពុងឈរកាន់ដៃមរកតនៅជិតលោកសុភា ទាំងលោកបន្លឺឡើងៈ

-ក្មួយវិចិត្រ ក្មួយមរកត មកណេះ មកស្គាល់គ្នាជាមួយកូនស្រីពូណា៎ ។

-បាទ ។

-ចាស ។

ទាំងវិចិត្រ ទាំងមរកតហាក់ដូចជាមិនពេញចិត្តនូវចរិកឬកពាកេសរី ឡើយ តែវាជាចាំបាច់នូវការរាក់ទាក់ជាមួយកញ្ញានិយមការរស់នៅបែបបស្ចិម ប្រទេសនេះ ។ សង្សារគូនេះកាន់ដៃគ្នាដើរត្រសងមករកលោកពន្លឺនិងបុត្រី ។ កេសរីយល់ភ័ក្ត្រស្រស់សង្ហារបស់វិចិត្រ នាងលាតដៃចេញពីការក្រសោបបិតា បែរមកចាប់ស្មាវិចិត្រទាំងពីរ ។ មុខនាងញញឹមដូចផ្ការីក សំលឹងកំលោះ វាចា រូសរាយភ្លាម :

-ហ្វាក ! នេះឬអ្នកនិពន្ធកំលោះដ៏ល្បីនោះ ? សង្ហាណាស់លោកវិចិត្រ ខ្ញុំរីករាយណាស់ដែលបានស្គាល់លោក ខ្ញុំជាកេសរីណា៎ ។

និយាយឃ្លានេះចប់ភ្លាម កេសរីងាកមកមើលមុខមរកតដែលមាន ភ័ក្ត្រស្មើ ។ ត្បិតស្រីមិនពេញចិត្តអាការៈកេសរីដែលប្រព្រឹត្តយ៉ាងស្និទ្ធជាមួយ

គូដណ្ដឹង មរកតមិនមែនជារុក្ខជាតិ នាងមានបេះដូងសាងពីសាច់និងឈាម ...ម្ដេសណាមិនហឺរ ។ កេសរីញញឹមស្រស់ហាក់គ្មានចាប់ភ្លឹក ចំពោះទឹកមុខមរកត ដែលតាមពិតចិត្តនាងយល់ឥតច្រលំពីក្ដីប្រចណ្ឌ ដែលលបលួចកើតក្នុងជីវន្តចិត្តមរកត ។ កេសរីស្រដីរាក់ទាក់បែបហ៊ី :

-បងស្រីខាងណោះ ពិតជាបងស្រីមរកតដែលជាគូដណ្ដឹងរបស់អ្នកនិពន្ធវិចិត្រមែនទេ ? បងស្រីមរកតពិតជាស្អាតណាស់ កេសរីសុំរាប់អានផង ។

-ចាស បងក៏សុំរាប់អានប្អូនកេសរីដែរ ។ "មរកតឆ្លើយទាំងប្រឹងញញឹម"

-បងស្រីហ្អាក ! ខានស្អែកនេះ បងបូរ៉ាជាតារាឯកប្រុសនឹងមកដល់ស្រុកយើង ។ មនុស្សទីមួយដែលខ្ញុំណែនាំឱ្យបងបូរ៉ាស្គាល់ គឺជាបងស្រីតែម្ដង ។ ព្រោះបងស្រីស្អាត បងបូរ៉ាសង្ហា។ អ្នកទាំងពីរ សមនឹងបានស្គាល់គ្នា សមណាស់ ។

មិនចាំបាច់ចំលើយឆ្លើយតបពីមាត់មរកត កេសរីបែរកាយមកសំពះលោកសុភា ទាំងនាងពោលៈ

- គឺពិតជាលោកអ៊ីសុភាមែនហើយ ។ លោកអ៊ី ! ខ្ញុំជំរាបសួរ ។

-ថ្វាយព្រះក្ដួយ គឺអ៊ីមែនហើយ ។ ចុះក្មួយមកតាមផ្លូវ អស់កម្លាំងដែរទេ ?

-ចាស ខ្ញុំអស់កម្លាំងខ្លះដែរលោកអ៊ី ។ តែពេលនេះ ខ្ញុំលែងអីហើយ ព្រោះខ្ញុំបានជួបមនុស្ស ដែលខ្ញុំចង់ជួបហើយ ។

និយាយចប់ នាងងាកមកសើចនឹងញាក់ចិញ្ចើមដាក់វិចិត្រ ក្នុងន័យបញ្ជាក់ប្រាប់ថា គឺនរៈជាអ្នកដែលនាងត្រូវការជួបនោះហើយ ។ កំលោះយើងហួសចិត្តនឹងឫកពារបស់ក្រមុំឆើត គេត្រឹមបានតែញញឹមស្ញើរ ជាការទទួលស្វាគមន៍នូវភាពស៊ីវិលយ័រាក់ទាក់របស់កញ្ញាតារាភាពយន្ត ។ ភ្លាមនោះ បាតដៃអ្នកប្រុសទទួលអារម្មណ៍មានចុងក្រចកមួយចុចជាខ្លាំង នាយដឹងភ្លាមថា ជាចុងក្រចករបស់ស្រីបណ្ដូលចិត្ត មាណពស្រវាក្ដោបដៃស្រីយ៉ាងណែន ជាសញ្ញាថា ខ្លួនគេមិនផ្ដេសផ្ដាសទេ គេលបមើលមុខមរកត គេឃើញនាងធ្វើងើយ ដោយបែរមើលទៅទិសឯណាឯណីហាក់ដូចជាគ្មានរឿងអ្វីកើតឡើងក្នុងចិត្តនាង ។ វិចិត្រធ្វើមុខញឹមៗ មិនស្ដី ។

លោកពន្លឺហាក់កាត់យល់នូវបរិយាកាសមិនស្រួលក្នុងចិត្តដែលកើតមានឡើង រវាងកំលោះក្រមុំទាំងពីរ ដែលមានមូលហេតុបង្កពីកេសរីជាកូនស្រីរបស់គាត់ លោកក៏ពោលឡើង :

-តោះ សុភាយើងបែកគ្នាត្រឹមនេះចុះ ។

-អើ បែកក៏បែក ។ អឺលាហើយក្មួយកេសរី ។

-ចាសអញ្ជើញលោកអ៊ំ ។ ចុះលោកវិចិត្រអញ្ជើញទៅជាមួយខ្ញុំឬទេ? ព្រោះខ្ញុំចង់ពិភាក្សា ពីការសំដែងតួនៅក្នុងរឿងដែលលោកនិពន្ធនោះណា ។

-រឿងដែលកូនចង់ពិភាក្សាជាមួយក្មួយចិត្រ ដូចជាមិនបន្ទាន់អីទៅពេលនេះទេកូនស្រី ។ កូនត្រូវតែរង់ចាំបូរ៉ាមកសិន សឹមនាំគ្នាពិភាក្សាជុំគ្នាតែម្តងណាំកូន ។ តោះ កូនស្រី យើងនាំគ្នាលាពួកគេចុះ ។

កេសរីមុខស្រុយ នាងមិនមានហារស្តី សុខចិត្តធ្វើតាមសំដីឪពុក ទាំងមួរហ្មងក្នុងចិត្ត ដោយពោលពាក្យទៅកាន់លោកសុភា :

-ខ្ញុំជំរាបលាលោកអី ។លាហើយអ្នកនិពន្ធរូបសង្ហា ។លាហើយបងស្រីមរកត ។

-ទៅចុះក្មួយ ។

-បាទ អញ្ជើញ ។

-ចាស អ្នកនាងកេសរី ។

-គ្នាលាហើយសុភា ។"ជាប្រយោគលោកពន្លឺ"

-ទៅចុះពន្លឺ ។

កេសរី និងលោកពន្លឺដើរសំដៅទៅរករថយន្តមួយ ។ឯវិចិត្រ មរកតដើរទៅរកយានរបស់អ្នកកំលោះ ។ ចំណែកលោកអតីតសាស្រ្តាចារ្យសុភា ក៏យាត្រាសំដៅរថយន្តរបស់លោកដែរ ។

......................................................................................................